# មាតិកា


**១. សេចក្តីផ្តើម** ....... 0

**២. ទស្សនវិស័យ និងគោលបំណង** ....... 2

២-១.ទស្សនវិស័យនៃផែនការគ្រប់គ្រង ....... 2

២-២ .គោលបំណង ....... 3

**៣. ស្ថានភាពសេដ្ឋកិច្ចសង្គម** ....... 3

៣-១. សមាជិក និងកម្រិតជីវភាព ....... 3

៣-៤. សមិទ្ធផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក ....... 5

៣-៥ បញ្ហាកំពុងជួបប្រទះ ....... 6

**៤ .ស្ថានភាពទូទៅនៃធនធានរបស់សហគមន៍** ....... 6

៤.១. ប្រវត្តិនៃធនធានធម្មជាតិ ....... 6

៤-២. ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍ ....... 6

៤-៣. តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍ ....... 7

**៥. យុទ្ធសាស្ត្រនៃការគ្រប់គ្រង** ....... 8

៥-១. រចនាសម្ព័ន្ធគ្រប់គ្រង ....... 8

៥-២. ការបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់ ....... 8

៥-២. គោលការណ៍ប្រើប្រាស់ធនធានធម្មជាតិ ....... 9

៥-៣. គោលការណ៍បែងចែកផលប្រយោជន៍ ....... 10

៥-៤. គោលការណ៍ស្វែងរកថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ ....... 10

**៦. ផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តរយៈពេល៥ឆ្នាំ( ២០១៨-២០២២ )** ... 12

**៧ .យន្តការត្រួតពិនិត្យ និងវាយតម្លៃ** ....... 24

**៨. តារាងឧបសម្ព័ន្ធ** ....... 26

## ១.សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ ក្រោមការសម្របសម្រួលរបស់ក្រុមការងារគម្រោង ការគ្រប់គ្រងធនធានបរិស្ថានតំបន់ឆ្នេរ(CZM-MoE(Danida) របស់ក្រសួងបរិស្ថាន សហការជាមួយមន្ទីរបរិស្ថានខេត្ត ដែនជម្រកសត្វព្រៃពាមក្រសោប ព្រមទាំងអាជ្ញាធរមូលដ្ឋាន។ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង គ្រប់គ្រងលើទំហំផ្ទៃដី៧២៨ហិចតា និងមានប្រកាសទទួលស្គាល់ដោយក្រសួងបរិស្ថានលេខ៣៥៨ ប្រក.បស្ត.កអធ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ ។

សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានទីតាំងស្ថិតនៅភូមិបឹងកាឆាង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា នៃដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង ដែលមានសមាជិកចូលរួមសរុបចំនួន ១៤១គ្រួសារ និងមានប្រជាជនសរុបចំនួន៦០៩នាក់ ស្រី៣០៦នាក់។

នៅក្នុងដំណើរការគ្រប់គ្រងនេះ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង បានខិតខំអនុវត្តកិច្ចការងារជាច្រើន ដូចជា ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការបោះបង្គោលព្រំប្រទល់សហគមន៍ ការដាក់ស្លាកសញ្ញាផ្សព្វផ្សាយ ការរៀបចំលក្ខន្តិកៈសហគមន៍ ការថែទាំដំណុះកូនកោងកាងធម្មជាតិ ការដាំស្តារព្រៃកោងកាង និងការរៀបចំចងក្រងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ ព្រមទាំងបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថានលើការងារគ្រប់គ្រងសហគមន៍ផងដែរ ។ ជាលទ្ធផល សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍។ លើសពីនេះទៀត សមិទ្ធផលដែលគួរឱ្យកត់សំគាល់គឺសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង បានបញ្ឈប់ទាំងស្រុងនូវអាជីវកម្មឡធ្យូងដែលកើតមាននៅក្នុងសហគមន៍កន្លងមក ព្រមទាំងបានរៀបចំសេវាអេកូទេសចរណ៍ ដែលជាប្រភពចំណូលមួយបន្ថែមទៀតសម្រាប់ជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់សមាជិកសហគមន៍។ ក្រៅពីលទ្ធផលដែលទទួលបានខាងលើសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ក៏មានការកើនឡើងនូវសមាជិកសហគមន៍ ព្រមទាំងសមត្ថភាពក្នុងការគ្រប់គ្រងផងដែរ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស។

ទោះបីជាសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ទទួលបាននូវសមិទ្ធផលជាច្រើនយ៉ាងណាក្តីក៏សហគមន៍ នៅមានបញ្ហាមួយចំនួនកំពុងជួបប្រទះនៅក្នុងដំណើរការគ្រប់គ្រងរបស់ខ្លួនផងដែរ ដូចជា សមត្ថភាពរបស់គណៈកម្មការលើការងារគ្រប់គ្រងសហគមន៍និងធនធានធម្មជាតិនៅមានកម្រិត បញ្ហាគ្រប់គ្រងសំរាម បញ្ហាបទល្មើសនេសាទនៅក្នុងតំបន់សហគមន៍ កង្វះធនធានមនុស្ស កង្វះសម្ភារៈសម្រាប់អនុវត្តន៍ និងកង្វះខាតទឹកសាបសម្រាប់បំរើសេចក្តីត្រូវការនៅក្នុងសហគមន៍ផងដែរ។

ដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្នុងមាត្រា២៨ ដែលតម្រូវឱ្យសហគមន៍មានផែនការគ្រប់គ្រងស្របជាមួយនឹងទិសដៅក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង សហគមន៍តំបន់

ការពារធម្មជាតិបឹងកាឆាង បានឈានដល់ការខំរៀបចំផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ(២០១៨-២០២២) ដែលក្នុងនោះ សហគមន៍បានធ្វើការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើរបស់សមាជិក និងការសិក្សាប៉ាន់ប្រមាណធនធានព្រៃឈើនៅក្នុងសហគមន៍ តាមរបៀបធ្វើសារពើភ័ណ្ឌព្រៃឈើ។ លទ្ធផលនៃការសិក្សាទាំងនោះបានផ្តល់នូវព័ត៌មាន និងទិន្នន័យជាមូលដ្ឋានសម្រាប់ពិគ្រោះយោបល់ក្នុងការរៀបចំផែនការគ្រប់គ្រងរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)។

ផែនការគ្រប់គ្រងនេះ គឺជាសមិទ្ធផលថ្មីមួយទៀត ដែលសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង សម្រេចបានព្រោះថាផែនការគ្រប់គ្រងនេះ កើតមានឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែង និងការចូលរួមរបស់សហគមន៍ហើយផែនការគ្រប់គ្រងនេះ គឺជាប្រទីបមួយសម្រាប់ចង្អុលបង្ហាញដល់ការអនុវត្តរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការងារអភិវឌ្ឍន៍របស់សហគមន៍។ លើសពីនេះទៀតផែនការគ្រប់គ្រងសហគមន៍នេះ ក៏ជាមធ្យោបាយមួយសម្រាប់ទាក់ទាញប្រភពថវិកាពីគម្រោង ដៃគូអភិវឌ្ឍន៍ ឬសប្បុរសជនដែលមានបំណងជួយគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍ផងដែរ។

ម្យ៉ាងវិញទៀត ផែនការគ្រប់គ្រងនេះពិតជានៅមានភាពខ្វះចន្លោះ ព្រោះថានេះជាលើកទីមួយដែលសហគមន៍បានរៀបចំឡើង។ ទោះបីជាយ៉ាងណា តាមរយៈនៃការអនុវត្តផែនការគ្រប់គ្រងនេះ សហគមន៍ពិតជាបានរៀនសូត្រ និងកែលម្អលើសកម្មភាពគ្រប់គ្រង ដោយផ្អែកតាមយន្តការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំនីមួយៗ។

## ២. ទស្សនវិស័យ និងគោលបំណង

### *២-១. ទស្សនវិស័យនៃផែនការគ្រប់គ្រង*

ដោយពិនិត្យទៅលើបញ្ហាដែលកំពុងជួបប្រទះនៅក្នុងដំណើរការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង បានកំណត់នូវទស្សនវិស័យ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងលើកទីមួយសម្រាប់ឆ្នាំ (២០១៨-២០២២) ពោល គឺ ធ្វើឱ្យប្រសើរឡើងទាំងកម្រិតជីវភាពរស់នៅរបស់សមាជិក និងធនធានព្រៃនៅក្នុងសហគមន៍។

ដើម្បីសម្រេចបានទស្សនវិស័យនេះ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង បានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការអនុវត្តផែនការគ្រប់គ្រងលើកទីមួយ(២០១៨-២០២២) ដូចខាងក្រោម៖

- ស្តារឡើងវិញនូវតំបន់ព្រៃវិចវិល តាមរយៈការថែរក្សាកូនដំណុះធម្មជាតិ និងការដាំកូនកោងកាងបន្ថែមនៅតាមចន្លោះព្រៃ
- ធ្វើឱ្យសមាជិកសហគមន៍មានជីវភាពប្រសើរជាងមុន តាមរយៈការរៀបចំសេវាអេកូទេសចរណ៍ ក្រុមសន្សំប្រាក់ ការរៀបចំអាជីកម្មខ្នាតតូច( ការផលិតទឹកត្រី និងបង្គាគ្រៀម)

- ធ្វើឱ្យសមាជិកសហគម៍រស់នៅប្រកបដោយសុខមាលភាពតាមរយៈការរៀបចំឱ្យមានអាងស្តុកទឹកភ្លៀង ការបំពាក់នូវបន្ទះថាមពលព្រះអាទិត្យនៅក្នុងសហគមន៍ ការសាងសង់បង្គន់អនាម័យសំរាប់ប្រើប្រាស់នៅតាមគ្រួសារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទំនប់ទឹកប្រៃ និងស្ពាននៅក្នុងសហគមន៍ផងដែរ
- ធ្វើឱ្យសមាជិកសហគមន៍មានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានតាមរយៈការពង្រឹងនូវសមត្ថភាព និងអភិបាលកិច្ចក្នុងការគ្រប់គ្រងសហគមន៍ ។

### *២-២ .គោលបំណង*

ការរៀបចំផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ធ្វើឡើងក្នុងគោលបំណងជាក់លាក់ ដូចខាងក្រោម៖

- កំណត់នូវទស្សនវិស័យ និងសកម្មភាពសំខាន់ៗដែលត្រូវអនុវត្តរយៈពេល៥ឆ្នាំ (២០១៨-២០២២) ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសហគមន៍
- កំណត់នូវគោលការណ៍ប្រើប្រាស់ឱ្យបានសមស្រប និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌និងតំលាភាពសំដៅធានាដល់ការគ្រប់គ្រងនៅក្នុងសហគមន៍ប្រកបដោយសុខដុមរមនា
- លើកកម្ពស់ប្រសិទ្ធភាពលើការគ្រប់គ្រងរបស់សហគមន៍ឱ្យមានលក្ខណៈបច្ចេកទេស ស្របតាមទិដ្ឋភាពច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

## ៣. ស្ថានភាពសេដ្ឋកិច្ចសង្គម

### *៣-១ សមាជិក និងកម្រិតជីវភាព*

សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានការចូលរួមពីប្រជាពលរដ្ឋក្នុងភូមិបឹងកាឆាង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដែលមានសមាជិកសរុបចំនួន **១៤១គ្រួសារ** ។ បច្ចុប្បន្ននេះមុខរបរសំខាន់ៗរបស់សហគមន៍គឺ ការនេសាទ។ ក្រៅពីនេះសមាជិកសហគមន៍មានមុខរបរបន្ទាប់បន្សំមួយចំនួនដូចជា៖ លក់កំលាំងពលកម្ម(ធ្វើកម្មកររោងចក្រ) និងលក់ដូរ។

ដោយឡែកទាក់ទងទៅនឹងកម្រិតជីវភាព ក្នុងពេលបច្ចុប្បន្ននេះសមាជិកសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានកម្រិតជីវភាពចែកចេញជាបីប្រភេទគឺ៖ សមាជិកដែលមានកម្រិតជីវភាពធូរធារ **១0%** មធ្យមប្រមាណ**៤៥%** សមាជិក ដែលមានកម្រិតជីវភាពក្រប្រមាណ**៤0%** និងសមាជិកដែលមានកម្រិតជីវភាពទីទាល់ក្រមានប្រមាណ**៥%**។




**កំណត់សំគាល់៖** ប្រភព TST ធ្វើនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ អ្នកចូលរួម២៨នាក់ ស្ត្រី៤នាក់។

### *៣-២ ស្ថានភាពសន្តិសុខស្បៀង*

ស្ថានភាពសន្តិសុខស្បៀងនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានទំនាក់ទំនងជាមួយនឹងប្រភពចំណូលដែលសហគមន៍ទទួលបាននៅកំឡុងឆ្នាំនីមួយៗ។ យោងតាមលទ្ធផលនៃកិច្ចពិភាក្សា និង ផ្តល់យោបល់ដោយគណៈកម្មការសហគមន៍បានឱ្យដឹងថា សមាជិកសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានប្រភពចំណូលមកពីការនេសាទ**៧0%** ការលក់កំលាំងពលកម្ម(កម្មកររោងចក្រ)ប្រមាណ **១៥%** ការលក់ដូរ**១៥%**។ បច្ចុប្បន្នសហគមន៍មានភាពប្រឈមជាមួយគ្រោះធម្មជាតិ បញ្ហាកង្វះដីសម្រាប់វិស័យកសិកម្ម និងទឹកសាបប្រើប្រាស់ ដែលបញ្ហានេះបានជះឥទ្ធិពលទៅដល់សន្តិសុខស្បៀងនៅក្នុងសហគមន៍ផងដែរ។ មធ្យោបាយដោះស្រាយសម្រាប់គ្រួសារដែលមានជីវភាពខ្វះខាតនិងទីទាល់ក្រទាំងនោះគឺពឹងអាស្រ័យលើមូលនិធិសហគមន៍។




**<u>កំណត់សំគាល់៖</u>** ប្រភព TST ធ្វើនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ អ្នកចូលរួម២៨នាក់ ស្ត្រី៤នាក់។

### *៣-៤ សមិទ្ធផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក*

នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍រយៈពេលជាង១០ឆ្នាំកន្លងមកនេះ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ទទួលបាននូវលទ្ធផលសំខាន់ៗមាន ដូចជា៖

- ការទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍
- រៀបចំសេវាអេកូទេសចរណ៍ ដែលជាប្រភពចំណូលមួយបន្ថែមទៀតសម្រាប់ជួយទ្រទ្រង់ជីវភាពរស់នៅរបស់សមាជិកសហគមន៍
- រៀបចំចងក្រងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍
- សាងសង់ទីស្នាក់សហគមន៍
- បោះបង្គោលព្រំប្រទល់សហគមន៍
- ការដេកហូតឈើសម្រាប់ឧបត្ថម្ភដល់សមាជិកសម្រាប់ការសាងសង់លំនៅដ្ឋាន
- ការកសាងសមត្ថភាពគណៈកម្មការសហគមន៍ និងការចូលរួមគាំទ្រពីសមាជិកសហគមន៍
- កិច្ចសហការគាំទ្រពីស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋានលើការងារគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសហគមន៍។

### ៣-៥ បញ្ហាកំពុងជួបប្រទះ

ទន្ទឹមនឹងភាពរីកចម្រើនដែលសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាងទទួលបាន សហគមន៍ក៏នៅមានបញ្ហាមួយចំនួនដែលកំពុងជួបប្រទះ ដូចជា៖

- បទល្មើសនេសាទពីអ្នកខាងក្រៅ នៅក្នុងដែនសហគមន៍
- ការរៀបចំសេវាកម្មអេកូទេសចរណ៍នៅមិនទាន់មានភាពច្បាស់លាស់
- សមត្ថភាពគណៈកម្មការសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅមានកម្រិត
- កង្វះទឹកសាបប្រើប្រាស់នៅក្នុងសហគមន៍
- កង្វះធនធានមនុស្សដើម្បីចូលរួមក្នុងការដឹកនាំការងារគ្រប់គ្រងធនធានធម្មជាតិ
- កង្វះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន និងទំនប់ទឹកការពារទឹកប្រៃ
- បញ្ហាគ្រប់គ្រងសំរាម
- កង្វះដីសម្រាប់អនុវត្តន៍វិស័យកសិកម្ម

## ៤ .ស្ថានភាពទូទៅនៃធនធានរបស់សហគមន៍

### ៤.១ ប្រវត្តិនៃធនធានធម្មជាតិ

ក្នុងអំឡុងទស្សវត្តឆ្នាំ១៩៩០ ធនធានធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោបត្រូវបានទទួលរងការបំផ្លិចបំផ្លាញស្ទើរខ្ទេចខ្ទីដោយសារការសកម្មភាពអាជីវកម្ម ការកាប់ដើមកោងកាងធ្វើឡធ្យូង ការរានដីធ្វើស្រែបង្គា និងការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់។ ចាប់ពីឆ្នាំ២០០១ ដល់ ២០០៣ សកម្មភាពបំផ្លាញធនធានធម្មជាតិត្រូវបានកាត់បន្ថយ តាមរយៈការបង្ក្រាបបទល្មើសពីអាជ្ញាធរដែនដី និងស្ថាប័នជំនាញ ព្រមទាំងមានការកសាងសមត្ថភាពពីស្ថាបន័ជំនាញ គម្រោង និងដៃគូអភិវឌ្ឍន៍។ ចាប់ពីឆ្នាំ២០០៨ ធនធានធម្មជាតិនៅក្នុងតំបន់នេះចាប់ពីផ្តើមមានភាពប្រសើឡើងវិញ តាមរយៈការដាំស្តារ និងពង្រឹងការអនុវត្តច្បាប់ ព្រមទាំងមានការចូលរួមគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន។

### ៤-២. ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍

ផ្អែកតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍ បានបង្ហាញឱ្យឃើញថា នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ដែលមានទំហំផ្ទៃដីព្រៃសរុបចំនួន៧២៨ហិចតា ក្នុងនោះសហគមន៍បានធ្វើការបែងចែកជាបីតំបន់សម្រាប់ធ្វើគ្រប់គ្រងនិងប្រើប្រាស់ ដែលរួមមាន តំបន់អេកូទេសចរណ៍ តំបន់ប្រើប្រាស់ និងតំបន់អភិរក្ស។ ដោយផ្អែកតាមលក្ខណៈភូមិសាស្ត្ររបស់សហគមន៍សម្រាប់ការធ្វើសារពើភ័ណ្ឌ សហគមន៍បានឯកភាពធ្វើសារពើភ័ណ្ឌតែនៅក្នុងតំបន់សម្រាប់ប្រើប្រាស់ដែលមានផ្ទៃដីទំហំ**៧៣ហិចតា** ។

តារាងលទ្ធផលសារពើភ័ណ្ឌធនធានព្រៃឈើនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង

| កូនដំណុះ | មុខកាត់តូចជាង ១០ស.ម | មុខកាត់ពី ១០ស.ម ទៅ ២០ស.ម | មុខកាត់ធំជាង ២០ស.ម |
|---|---|---|---|
| ១២០០ដើម/ហិចតា | ៩៥០ដើម/ហិចតា | ២៤០០ដើម/ហិចតា | មានតិចតួច |

តារាងសរុបចំនួនដើមឈើនៅផ្ទៃដី ៧៣ហិចតា

| កូនដំណុះ | មុខកាត់តូចជាង ១០ស.ម | មុខកាត់ពី ១០ស.ម ទៅ ២០ស.ម | មុខកាត់ធំជាង ២០ស.ម |
|---|---|---|---|
| ៨៧.៦០០ដើម | ៦៩.៣៥០ដើម | ១៧៥.២០០ដើម | មានតិចតួច |

(ប្រភព: ការសិក្សាប៉ាន់ប្រមាណពីធនធានព្រៃឈើនៅក្នុងសហគមន៍ ខែមេសា ឆ្នាំ ២០១៦)

### *៤-៣ តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍*

តាមលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើនៅក្នុងសហគមន៍ អាចកំណត់បានពីប្រភេទផលនិងអនុផលព្រៃឈើ ដែលជាតម្រូវការប្រើប្រាស់ចាំបាច់របស់សមាជិកសហគមន៍ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតប្រចាំឆ្នាំ។ ម៉្យាងទៀតលទ្ធផលនៃការសិក្សានេះ បានបង្ហាញអំពីបរិមាណនៃការប្រើប្រាស់ផល-អនុផលព្រៃឈើក្នុងរយៈមួយឆ្នាំនៅសហគមន៍។ ជាមួយគ្នា នេះយើងជឿជាក់ថាតួលេខនៃការប៉ាន់ប្រមាណទាំងនេះប្រាកដជាមានភាពលំអៀង ព្រោះថាព័ត៌មានដែលផ្តល់ឱ្យតាមរយៈសមាជិកសហគមន៍នៅមានលក្ខណៈមិនប្រាកដ មិនជាក់លាក់ ហើយម៉្យាងទៀតបរិមាណនៃការប្រើប្រាស់នៅក្នុងគ្រួសារនីមួយៗ អាចមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យលើតម្រូវការទីផ្សារ និងការកើនឡើងនូវចំនួនសមាជិកនៅក្នុងគ្រួសារនីមួយៗផងដែរ។

តារាងសិក្សាពីតម្រូវការប្រើប្រាស់ផល-អនុផលឈើជាមធ្យមនៅក្នុងសហគមន៍

| ល.រ | ប្រភេទឈើ | ចំនួនដើមឈើដែលប្រើប្រាស់សម្រាប់ជួសជុលផ្ទះក្នុង១គ្រួសារ | ចំនួនដើមឈើសម្រាប់ការសាងសង់ផ្ទះថ្មី ក្នុង១សារ |
|---|---|---|---|
| ១ | កោងកាង | ១៥ - ២០ ដើម | ៥០ - ១០០ ដើម |
| ២ | ស្មែរ | ១ ដើម | ៥ - ១៥ ដើម |
| ៣ | ក្រវិញ | ១ ដើម | ៥ - ១៥ ដើម |

| | | | |
|---|---|---|---|
| ៤ | ក្រញឹប | ៦ ដើម | ៥ - ១០ ដើម |
| ៥ | ស្នាច់ | ៥ ដើម | ៥ - ១០ ដើម |

(ប្រភព: ការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ ខែមេសា ឆ្នាំ ២០១៦)

## ៥. យុទ្ធសាស្ត្រនៃការគ្រប់គ្រង

### *៥-១. រចនាសម្ព័ន្ធគ្រប់គ្រង*

សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានសមាសភាពគណៈកម្មការចំនួន ៧នាក់ ក្នុងនោះមានស្ត្រីចំនួន៤នាក់ និងអមដោយទីប្រឹក្សាដែលមានមេភូមិ និងអ្នកគាំទ្ររួមមាន មន្ទីរបរិស្ថាន ដែនជម្រកសត្វព្រៃពាមក្រសោប គម្រោង និងអង្គការដៃគូ ។ សមាសភាពគណៈកម្មការទាំងនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយសេរី និងមានដេកាទទួលស្គាល់ពីមេឃុំ។




### *៥-២. ការបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់*

ដោយផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនិងប្រភេទព្រៃ សហគមន៍បានធ្វើការបែងចែកជា **៣តំបន់**សំខាន់ៗដើម្បីធ្វើការគ្រប់គ្រងនិងការប្រើប្រាស់ ដែលរួមមាន៖ តំបន់ប្រើប្រាស់ តំបន់អភិរក្ស និងតំបន់អេកូទេសចរណ៍(ដូចមានផែនទីបង្ហាញក្នុងតារាង៦ឧបសម្ព័ន្ធ)។ គោលបំណងនៃការគ្រប់គ្រង និងការប្រើប្រាស់ក្នុងតំបន់នីមួយៗមានដូចខាងក្រោម៖

**តំបន់ប្រើប្រាស់** : តំបន់ប្រើប្រាស់នេះមានទំហំផ្ទៃដីសរុប **៧៣ហិចតា** គោលបំណងនៃការគ្រប់គ្រងតំបន់នេះ គឺដើម្បីធ្វើការដកហូត និងប្រើប្រាស់ជាលក្ខណៈប្រពៃណី និងសម្រាប់សមាជិកធ្វើការសាងសង់ និងជួសជុលលំនៅដ្ឋាន ការប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ ព្រមទាំងសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងសហគមន៍។

**តំបន់អភិរក្ស** : តំបន់នេះមានទំហំផ្ទៃដី**៥១២ហិចតា** គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅ

ការថែរក្សាកូនជំណុះធម្មជាតិ ជីវចម្រុះ ប្រភេទឈើសំខាន់ៗ និងសម្រាប់អភិរក្សត្រីមេពូជ។ នៅតំបន់នេះ មិនអនុញ្ញាតឱ្យធ្វើការដកហូតផល អនុផលព្រៃឈើគ្រប់ប្រភេទ ប៉ុន្តែសមាជិកសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាងអាចធ្វើការនេសាទជាលក្ខណៈគ្រួសារ ដោយគោរពទៅតាមលក្ខន្តិកៈរបស់សហគមន៍។

**តំបន់អេកូទេសចរណ៍** : តំបន់ទេសចរណ៍ធម្មជាតិមានទំហំផ្ទៃដី **១៤៣ហិចតា** គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅថែរក្សាការពារជីវចម្រុះ និងធនធានធម្មជាតិ សម្រាប់ការផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងសហគមន៍។ ជាពិសេសការគ្រប់គ្រងតំបន់នេះសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ សំដៅបង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍ តាមរយៈការផ្តល់សេវាអេកូទេសចរណ៍ផ្សេងៗ។ នៅក្នុងតំបន់នេះមិនអនុញ្ញាត្តឱ្យមានការដកហូត និងប្រើប្រាស់ធនធានព្រៃឈើគ្រប់ប្រភេទ ពោលគឺ រក្សាទុកដើម្បីភាពទាក់ទាញសម្រាប់បំរើឱ្យវិស័យអេកូទេសចរណ៍តែប៉ុណ្ណោះ។

## *៥-២ គោលការណ៍ប្រើប្រាស់ធនធានធម្មជាតិ*

ដោយយោងទៅតាមស្ថានភាពព្រៃ និងតម្រូវការប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សមាជិកសហគមន៍ ការរៀបចំផែនការគ្រប់គ្រងលើកទីមួយ(២០១៨-២០២២) សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង បានកំណត់នូវគោលការណ៍ប្រើប្រាស់ ដូចខាងក្រោម៖

- មិនអនុញ្ញាត្តឱ្យកាប់ឈើគ្រប់ប្រភេទដើម្បីធ្វើអាជីវកម្មឡើយ
- មិនអនុញ្ញាត្តឱ្យដកហូតនិងប្រើប្រាស់ឈើសំរាប់ប្រើប្រាស់ជាមធ្យោបាយនេសាទឡើយ
- សំរាប់ការសាងសង់លំនៅដ្ឋានថ្មី( សសរ ផ្ទោង និងរបា ) អាចអនុញ្ញាត្តបានត្រឹម **៣ខ្នងផ្ទះ ក្នុងមួយឆ្នាំ** ហើយលទ្ធភាពនៃការផ្តល់ឈើ ជូនត្រឹមតែ៦០ ទៅ ៧០ដើម ក្នុងមួយខ្នងផ្ទះ
- សំរាប់ការជួលជុលលំនៅដ្ឋាន( សសរ ផ្ទោង និងរបា ) សហគមន៍អនុញ្ញាត្តបានត្រឹម **១០ខ្នងផ្ទះក្នុងមួយឆ្នាំ** និងហើយលទ្ធភាពនៃការផ្តល់កូនឈើ ជូនត្រឹមតែ១៥ដើម ទៅ២០ដើម ក្នុងមួយខ្នងផ្ទះ ហើយរយៈពេល៣ឆ្នាំទើបស្នើសុំជួលជុលម្តងទៀត
- ចំពោះការប្រើប្រាស់ឈើសម្រាប់សាងសង់ទ្រុងជ្រូក មាន់ ទា សហគមន៍ផ្តល់ជូនទៅតាមទំហំនៃការស្នើសុំ
- ការសម្រេចផ្តល់ឈើទៅឱ្យគ្រួសារជាសមាជិកណាមួយ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍
- ការដកហូតឈើសំណង់ អាចធ្វើឡើងតែនៅក្នុងតំបន់ប្រើប្រាស់ និងកាប់តាមរបៀបជ្រើសរើស
- ប្រជាជនដែលមិនមែនជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មិនអនុញ្ញាត្តឱ្យប្រើប្រាស់ធនធានព្រៃឈើនៅក្នុងតំបន់ព្រៃសហគមន៍ឡើយ

- ក្នុងករណីមានតម្រូវការប្រើប្រាស់ឈើសំរាប់បំរើសេចក្តីត្រូវការនៅក្នុងសហគមន៍( សាលារៀន ស្នាក់ការសហគមន៍ វត្តអារាម ស្ពាន..) គណៈកម្មការសហគមន៍ត្រូវប្រជុំពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ជាមុនសិន
- ការដកហូតនិងប្រើប្រាស់ធនធានព្រៃឈើនៅក្នុងសហគមន៍ ត្រូវធ្វើលិខិតជាលាយលក្ខអក្សរទៅគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ដោយមានការដឹងឮពីក្រុមប្រឹក្សាឃុំនិងមានការឯកភាពពីនាយកដែនជម្រកសត្វព្រៃពាមក្រសោប ។

### *៥-៣. គោលការណ៍បែងចែកផលប្រយោជន៍*

ការបែងចែកផលប្រយោជន៍ គឺជាកត្តាសំខាន់មួយនៅក្នុងការគ្រប់គ្រងសហគមន៍ ប្រសិនបើការបែងចែកផលប្រយោជន៍ មិនប្រកបដោយសមធម៌ គ្មានតម្លាភាព នោះវាជាមូលហេតុធ្វើឱ្យមានទំនាស់កើតឡើង ឬអាចឈានទៅដល់ភាពបរាជ័យនៅក្នុងការគ្រប់គ្រងរបស់សហគមន៍ទាំងមូល។ សម្រាប់ការរៀបចំផែនការគ្រប់គ្រងលើកទីមួយនេះ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង បានកំណត់នូវគោលការណ៍បែងចែកផលប្រយោជន៍មួយចំនួន ដូចខាងក្រោម៖

- គ្រួសារទីទាល់ក្រ និងងាយរងគ្រោះ ដែលជាសមាជិកសហគមន៍មានអាទិភាពក្នុងការទទួលបានឈើសម្រាប់ការជួសជុល និងសាងសង់លំនៅដ្ឋានថ្មី
- ថវិកាសហគមន៍ដែលទទួលបានពីគ្រប់ប្រភពទាំងអស់ មិនអនុញ្ញាតឱ្យធ្វើការប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ពោលគឺទុកសម្រាប់បម្រើផលប្រយោជន៍រួមលើការងារអភិរក្ស និងការងារអភិវឌ្ឍន៍នៅក្នុងសហគមន៍តែប៉ុណ្ណោះ

### *៥-៤ គោលការណ៍ស្វែងរកថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ*

- ប្រភពប្រាក់ចំណូលសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង រួមមាន៖
  - សេវាអេកូទេសចរណ៍
  - ការប្រាក់ពីក្រុមសន្សំ
  - ប្រាក់ភាគទានសមាជិកសហគមន៍
  - ប្រាក់ចំណូលពីដកហូតផលព្រៃឈើ
  - សំណងការខូចខាត
  - ប្រាក់ចំណូលពីការបង់សេវាបរិស្ថាននៅក្នុងសហគមន៍
  - សប្បុរសជន
- ប្រាក់ចំណូលដែលបានមកពីគ្រប់ប្រភពទាំងអស់ត្រូវដាក់បញ្ចូលនៅក្នុងកេសសហគមន៍តែមួយ និងមានការកត់ត្រាក្នុងបញ្ជីច្បាស់លាស់ដោយហិរញ្ញិករបស់សហគមន៍

- នៅក្នុងផ្នែកនីមួយៗត្រូវមានអ្នកទទួលខុសត្រូវកត់ត្រាម្នាក់មុននឹងផ្ទេរប្រាក់ចូលទៅក្នុងកេសសហគមន៍
- ថវិកាតំកល់ទុកក្នុងកេសសហគមន៍អាចរក្សាត្រឹមតែ **១០០០.០០០រៀល**(មួយលានរៀល) ប្រសិនបើលើសពីនេះ ត្រូវទុកប្រើប្រាស់ជាទុនបង្វិលសម្រាប់ក្រុមសន្សំក្នុងសហគមន៍ឬផ្ញើនៅធនាគាដែលនៅជិតសហគមន៍
- ហិរញ្ញិកសហគមន៍ត្រូវធ្វើការបូកសរុប និងរាយការណ៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំខែនីមួយៗ
- គណៈកម្មការត្រូវធ្វើរបាយការណ៍សង្ខេបពីលទ្ធផលសកម្មភាពការងារគ្រប់គ្រងសហគមន៍ទៅនាយកដែនជម្រកសត្វព្រៃពាមក្រសោប និងចំលងជូនក្រុមប្រឹក្សាឃុំប៉ាក់ខ្លង នៅរៀងរាល់**៣ខែ**ម្តង
- គណៈកម្មការត្រូវប្រជុំរាយការណ៍ពីលទ្ធផលសកម្មភាពនៃការគ្រប់គ្រងសហគមន៍ទៅដល់សមាជិកសហគមន៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំឆ្នាំរបស់សហគមន៍
- ថវិកាចំណូលប្រចាំឆ្នាំក្នុងកេសសហគមន៍ដែលបានមកពីគ្រប់ផ្នែកទាំងអស់ត្រូវធ្វើការបែងចែកទៅលើ៖ ការងារអភិរក្ស **២០%** ការងារអភិវឌ្ឍន៍ **១០%** ការងារជួយសង្គ្រោះដល់សមាជិកសហគមន៍ **៣០%** ការងាររដ្ឋបាល**២០%** ការងារវិស័យអប់រំ**៥%** និងសំរាប់តំកល់ទុកក្នុងកេសសហគមន៍ចំនួន**១៥%**
- ករណីសហគមន៍មានប្រាក់ចំណូលពីសេវាអេកូទេសចរណ៍ សហគមន៍នឹងធ្វើការបែកចែកថវិកាចំនួន**៣%**(បីភាគរយ) សម្រាប់ជាការរួមចំណែកក្នុងការចូលរួមគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប។

## ៦. ផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តរយៈពេល៥ឆ្នាំ(២០១៨-២០២២)

ដោយយោងទៅតាមទស្សនវិស័យរបស់សហគមន៍ក្នុងការរៀបចំ និងអនុវត្តន៍ផែនការគ្រប់គ្រងលើកទីមួយ(២០១៨-២០២២) សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាងបានកំណត់សកម្មភាពចំបងៗ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| ១ | រៀបចំកែសម្រួលលក្ខន្តិកៈសហគមន៍ និងរៀបចំកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថានលើការងារគ្រប់គ្រងធនធានធម្មជាតិ | x | | | | | |
| ២ | រៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការអាណត្តិថ្មី(អាណត្តិទី៦) | x | | | | | |
| ៣ | ការងារល្បាត | x | x | x | x | x | |
| ៤ | ជួសជុលថ្នាលបណ្តុះកូនកោងកាង និងដាំស្តារព្រៃកោងកាង | x | x | | | | ចំនួន១៥ហិចតា |
| ៥ | ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចក្នុងសហគមន៍(ផ្លូវទំនប់ភ្លោះទឹកកណ្តាល២គីឡូម៉ែត្រ ស៊ីទែនទឹកគ្រង់ទឹកភ្លៀង ស្ថានីយ៍សាកអាគុយដោយប្រើថាមពលព្រះអាទិត្យ និងធុងចំរោះ) | x | x | | | | |
| ៦ | ការកសាងសមត្ថភាពដល់គណៈកម្មការ(ការងារគ្រប់គ្រងថវិកា ការសរសេរគម្រោងខ្នាតតូច ការសរសេរធ្វើរបាយការណ៍ ការសរសេរកំណត់ហេតុ និងការគ្រប់គ្រងធនធានធម្មជាតិ) | x | x | x | x | X | |
| ៧ | ពង្រឹងការងារគ្រប់គ្រងប្រាក់សន្សំ និងឥណទាននៅក្នុងសហគមន៍ | x | x | x | x | x | |
| ៨ | ការងារផ្សព្វផ្សាយ និងផ្តល់បទពិសោធន៍លើការងារគ្រប់គ្រងសហគមន៍ | x | X | x | x | x | |
| ៩ | សិក្សាសក្តានុពល និងរៀបចំសេវាអេកូទេសចរណ៍នៅក្នុងសហគមន៍ | x | x | x | x | x | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | ការធ្វើអាជីវកម្មខ្នាតតូចដើម្បីលើកកម្ពស់ជីវភាពសហគមន៍(ធ្វើទឹកត្រីបង្គាគ្រៀម) និងការចិញ្ចឹមឧឡុងនៅក្នុងព្រៃកោងកាង | x | X | x | x | x | |
| ១១ | រៀបចំផែនការគ្រប់គ្រងសហគមន៍លើកទី២ | | | | | x | |
| ១២ | ការងារពង្រឹងវិស័យអប់រំដល់កុមារនៅក្នុងសហគមន៍ | x | x | x | x | x | |
| ១៣ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | x | x | x | x | X | |
| ១៤ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំរបស់សហគមន៍ | x | x | x | x | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០១៨

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ | | | | | | x | | | | | | x | |
| ៣ | ការងារឃាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | ធ្វើផ្ទាំងផែនទីសហគមន៍ដាក់ស្លាកសញ្ញាសំគាល់ព្រំប្រទល់សហគមន៍ | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | | | | | x | | | | | | x | | ២ផ្ទាំង |
| ៥ | ជួសជុលថ្នាលនិងបណ្ដុះកូនកោងកាង | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | x | x | x | | | | | | | |
| ៦ | ពិធីដាំកូនកោងកាង | ព្រៃសហគមន៍ | គណៈកម្មមការ និងសមាជិក | | | | | | x | x | x | | | | | |
| ៧ | សិក្សាពីសក្ដានុពលតំបន់អេកូទេសចរណ៍ | ព្រៃសហគមន៍ | គណៈកម្មការ | | | x | x | x | x | | | | | | | |
| ៨ | សិក្សារៀបចំផ្ទះស្នាក់នៅ អ្នកនាំភ្ញៀវ និងសេវានានាសម្រាប់ភ្ញៀវទេសចរណ៍ | សហគមន៍ | គណៈកម្មការ | | | | | | | | | | | | | ៤ផ្ទះ |
| ៩ | រៀបចំទីតាំងចិញ្ចឹមក្ដាមជាលក្ខណៈគ្រួសារ | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | x | x | x | x | x | x | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១០ | ការងារគ្រប់គ្រងនិងពង្រឹងក្រុមសន្សំប្រាក់ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ១១ | រៀបចំអាងត្រង់ទឹកភ្លៀងសហគមន៍ បន្ទះថាមពលព្រះអាទិត្យ និងចែកចាយធុងចំពោះតាមគ្រួសារ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | x | x | x | x | | | ៥ស៊ីទែន ធុងចំពោះ១០០ធុង |
| ១២ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | | |
| ១៣ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០១៩

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | X | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ | | | | | | x | | | | | | x | |
| ៣ | ការងារឃាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | X | x | x | x | x | x | x | x | x | x | x | |
| ៤ | រៀបចំថ្នាល និងបណ្តុះកូនកោងកាង | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | x | x | x | | | | | | | |
| ៥ | ពិធីដាំកូនកោងកាង | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | x | x | | | | | |
| ៦ | រៀបចំកន្លែងលក់ផលនេសាទ | សហគមន៍ | គណៈកម្មការ | | | | | | | | | | x | x | x | |
| ៧ | រៀបចំក្រុមអ្នកនាំភ្ញៀវ និងក្រុមអាហារដ្ឋានសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | | | | | | | | | | ៥នាក់ |
| ៨ | សាងសង់ស្ពានអបតាមដៃព្រែក | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | x | x | x | ១០០០ម៉ែត្រ |
| ៩ | សាងសង់ខ្ទះសម្រាប់ភ្ញៀវទេសចរ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | x | x | x | x | x | |
| ១០ | រៀបចំទូកអុំកំសាន្តតាមដៃព្រែកនិងកាណូតដឹកភ្ញៀវទេសចរ | សហគមន៍ | គណៈកម្មការ | | | | | | x | x | x | x | | | | ទូក២គ្រឿង<br>ទូកម៉ាស៊ីន៤គ្រឿង |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១ | រៀបចំខិតបណ្ណផ្សព្វផ្សាយពីតំបន់អេកូទេសចរណ៍និងសេវាកម្មនានា | | | | | | | x | x | | | | | | | |
| ១២ | ផ្សព្វផ្សាយផែនការគ្រប់គ្រង | | | x | x | | | | | | | | | | | |
| ១៣ | ការងារគ្រប់គ្រង និងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | | | x | x | x | x | x | x | x | x | x | x | x | x | |
| ១៤ | រៀបចំទីតាំងចាក់សំរាម | | | x | x | x | | | | | | | | | | |
| ១៥ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | | | | | | | | x | | | | | | | |
| ១៦ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | គណៈកម្មការនិងសមាជិក | គណៈកម្មការនិងសមាជិក | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០២០

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | រៀបចំតំបន់អភិរក្សត្រីមេពូជនិងក្តាម សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ | តំបន់អភិរក្ស | គណៈកម្មការ និងសមាជិក | x | x | | | | | | | | | | | |
| ៥ | រៀបចំសំអាតផ្លូវខ្សាច់ និងសាងសង់ខ្ទះសម្រាប់ភ្ញៀវអង្គុយលេង | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | x | x | | | | | | | | | ១៨០០ម៉ែត្រ ខ្ទះចំនួន១០ |
| ៦ | វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំបដិសណ្ឋាកិច្ចនិងរៀបចំសេវាអេកូទេសចរណ៍ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | x | x | | | | | | | | |
| ៧ | ការងារគ្រប់គ្រងនិងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៨ | ការងារគ្រប់គ្រងសំរាម | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៩ | វគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រងថវិកា និងបដិសណ្ឋាកិច្ច | ស្នាក់ការ | គណៈកម្មការនិងក្រុមផ្តល់សេវា | x | x | | | | | | | | | | | |
| ១០ | រៀបចំចងក្រងគ្រួសារចាប់អារម្មណ៍ធ្វើបង្គាគ្រៀម និងទឹកត្រី | ស្នាក់ការ | គណៈកម្មការ និងគ្រួសារចាប់អារម្មណ៍ | | x | x | | | | | | | | | | |
| ១១ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការនិងសមាជិក | | | | | | x | | | | | | | |
| ១២ | សន្និបាតបូកសុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | ស្នាក់ការ | គណៈកម្មការនិងសមាជិក | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០២១

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | សិក្សានិងរៀបតំបន់អំពិលអំពែកសម្រាប់ទាក់ទាញភ្ញៀវទេសចរ | ព្រៃសហគមន៍ | គណៈកម្មការ | x | x | | | | | | | | | | | |
| ៥ | សាងសង់ស្ពានថ្មពីដៃព្រែកក្នុងឆ្ពោះទៅកាន់ធ្នេរខ្សាច់កាត់តាមព្រៃកោងកាង | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | x | x | | | | | | | | | ៧០០ម៉ែត្រ |
| ៦ | រៀបចំ និងកែលម្អកន្លែងងូតទឹក | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | x | x | | | | | | | | | | | |
| ៧ | ជួសជុលនិងធ្វើខ្ទះថ្មីនៅក្នុងតំបន់អេកូទេសចរណ៍ | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | x | x | | | | | | | | | |
| ៨ | រៀបចំនិងកែសម្រួលទីកន្លែងចាក់សំរាម | សហគមន៍ | សហគមន៍ | | | | | | | | | | | x | x | |
| ៩ | ពង្រឹងនិងពង្រីកគ្រួសារធ្វើ | សហគមន៍ | សហគមន៍ | | | | | | x | x | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បង្គាត្រៀម និងធ្វើទឹកត្រី | | | | | | | | | | | | | | | |
| ១០ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | | |
| ១១ | សន្និបាតបូកសុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | ស្នាក់ការ | ស្នាក់ការ | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០២២

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | សាងសង់ផ្ទះស្នាក់នៅសំរាប់ភ្ញៀវទេសចរនៅតំបន់ឆ្នេរខ្សាច់ក្នុងព្រៃកោងកាង | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | x | x | | | | | | | | | | | ១ខ្នងផ្ទះ |
| ៥ | រៀបចំទីកន្លែងនេសាទតាមបែបសហគមន៍សម្រាប់ភ្ញៀវទេសចរ | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | | | | | x | x | | | | | |
| ៦ | បង្កើតមជ្ឈមណ្ឌលព័ត៌មានសហគមន៍ | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | | x | x | ១កន្លែង |
| ៧ | រៀបចំអាហារសហគមន៍សម្រាប់ផ្តល់សេវាដល់ភ្ញៀវទេសចរណ៍ | តំបន់អេកូទេសចរណ៍ | គណៈកម្មការ និងសមាជិក | | | x | x | | | | | | | | | ១កន្លែង |
| ៨ | បោះឆ្នោតជ្រើសរើសគណៈកម្មការអាណត្តិថ្មី | ស្នាក់ការ | គណៈកម្មការ និងសមាជិក | x | x | | | | | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៩ | រៀបចំផែនការគ្រប់គ្រងសំរាប់ ៥ឆ្នាំបន្ទាប់ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | x | x | x | x | x | | | | | | | | |
| ១០ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | | |
| ១១ | សន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំរបស់សហគមន៍ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |

## ៧.យន្តការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យនិងវាយតម្លៃ គឺជាមធ្យោបាយមួយដ៏សំខាន់សម្រាប់ជួយពង្រឹងដល់ដំណើរការអនុវត្តរបស់សហគមន៍ ក្នុងដំណើរការគ្រប់គ្រងធនធានធម្មជាតិ ក៏ដូចជាការងារអភិវឌ្ឍន៍អេកូទេសចរណ៍ ព្រមទាំងជួយសម្រេចឱ្យបាននូវគោលបំណង និងទស្សនវិស័យរបស់សហគមន៍។ ដំណើរការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងនេះ សហគមន៍បានកំណត់នូវយន្តការត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្អែកលើគោលការណ៍ទាំងបួននៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ប្រកបដោយនិរន្តរភាព ដូចមានខ្លឹមសារនៅក្នុងតារាងខាងក្រោម៖

**គោលការណ៍ទី១ ៖ ធនធានធម្មជាតិត្រូវបានថែរក្សា**

| លរ. | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | ការកំណត់តំបន់គ្រប់គ្រងច្បាស់លាស់ | មានផែនទីបង្ហាញពីតំបន់ព្រៃសហគមន៍ ចំនួនពីរផ្ទាំងសម្រាប់ផ្សព្វផ្សាយក្នុងសហគមន៍ |
| | | មានព្រំប្រទល់ច្បាស់លាស់ |
| | | សមាជិកសហគមន៍ ៨០% ស្គាល់ព្រំប្រទល់ព្រៃសហគមន៍ច្បាស់ |
| ២ | ជីវៈចម្រុះត្រូវបានថែរក្សា | ផ្ទៃដីចំនួន១៥ហិចតា ត្រូវបានដាំដុះកូនឈើឡើងវិញ |
| | | ប្រភេទសត្វមួយចំនួនមានការកើនឡើងក្នុងតំបន់ព្រៃសហគមន៍ |
| | | ប្រភេទឈើកម្រ និងធនធានជលផលត្រូវបានថែរក្សាការពារ |
| | | កូនដំណុះធម្មជាតិត្រូវបានថែរក្សា |

**គោលការណ៍ទី២ ៖ សុខមាលភាពសមាជិកត្រូវបានធ្វើឱ្យប្រសើរឡើង**

| លរ. | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| | ធនធានព្រៃសហគមន៍បានរួមចំណែកទ្រទ្រង់ជីវភាពរស់នៅរបស់សមាជិកសហគមន៍ | សមាជិកសហគមន៍៨០%បានប្រើប្រាស់ផលអនុផលពីព្រៃសហគមន៍សម្រាប់ជីវភាពរស់នៅ |
| | | សមាជិកសហគមន៍២០%ទទួលបានប្រាក់ចំណូលពីការផ្តល់សេវាអេកូទេសចរណ៍ |
| | | យ៉ាងហោចណាស់សមាជិកសហគមន៍១៣គ្រួសារ ក្នុងមួយឆ្នាំអាចទទួលបានឈើសំរាប់ជួសជុល និងសាងសង់លំនៅដ្ឋាន |
| ២ | | ស្ត្រីជាសមាជិកសហគមន៍១០% ទទួលបានប្រាក់ចំណូលពីផ្នែកសេវាអេកូទេសរណ៍ |

| | | |
|---|---|---|
| | ប្រភពចំណូលពីសេវាអេកូទេសចរណ៍ | សមាជិកដែលមានជីវភាពទីទាល់ក្រទទួលបានសៀងសង្គ្រោះពីមូលនិធិសហគមន៍ |
| | | សមាជិកសហគមន៍ ៨០% ទទួលបានទឹកសាបប្រើប្រាស់គ្រប់គ្រាន់ |

## គោលការណ៍ទី៣ ៖ សុខមាលភាពសហគមន៍ត្រូវបានធានា

| ល.រ. | លក្ខណៈវិនិច្ឆ័យ | សុចនាករ |
|---|---|---|
| ១ | គណៈកម្មការសហគមន៍មានសមត្ថភាពដឹកនាំ | ទំនាស់ផ្សេងៗក្នុងសហគមន៍នឹងត្រូវបានដោះស្រាយដោយគណៈកម្មការ |
| | | ការគ្រប់គ្រងថវិកាមានភាពច្បាស់លាស់និងតម្លាភាព |
| | | ថវិកាសហគមន៍មានការកើនឡើង |
| ២ | ការចូលរួមរបស់សមាជិកសហគមន៍ | រាល់ការប្រជុំនឹងមានសមាជិកចូលរួមលើសពី៦០% |
| | | សមាជិក៨០%បានចូលរួមយាមល្បាតនិងទប់ស្កាត់បទល្មើស |
| | | ៨០%នៃសមាជិកហ៊ានរាយការណ៍ពីអ្នកធ្វើបទល្មើសក្នុងព្រៃសហគមន៍ |
| | | សមាជិក៨០%បានសុំការអនុញ្ញាតពីគណៈកម្មការមុនការនឹងធ្វើការដេកហូត និងប្រើប្រាស់ធនធាន |

## គោលការណ៍ទី៤ ៖ មានការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅ

| ល.រ. | លក្ខណៈវិនិច្ឆ័យ | សុចនាករ |
|---|---|---|
| ១ | ការចូលរួមពីក្រុមប្រឹក្សាឃុំ | កិច្ចប្រជុំនៅក្នុងសហគមន៍មានការចូលរួមពីក្រុមប្រឹក្សាឃុំ និងដែនជម្រកសត្វពាមក្រសោប |
| | | ៥០%នៃផែនការសកម្មភាពរបស់សហគមន៍ត្រូវបានដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ |
| ២ | ការគាំទ្រពីស្ថាប័នជំនាញ | ផែនការគ្រប់គ្រងសម្រាប់រយៈពេល៥ឆ្នាំ(២០១៨-២០២២) ត្រូវបានគាំទ្រពីអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានក្រសួងបរិស្ថាន |

តារាងសកម្មភាពសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ

| ល.រ | សកម្មភាព | អ្នកចូលរួម | វិធីសាស្ត្រ | ប្រធានបទ |
|---|---|---|---|---|
| ១ | ប្រជុំប្រចាំខែ | ប្រធានក្រុម, គណៈកម្មការ និងទីប្រឹក្សា | ប្រជុំពិភាក្សារួម | - ពិនិត្យលើផែនការប្រចាំខែ<br>- ដោះស្រាយបញ្ហាដែលកើតមាន |
| ២ | ប្រជុំប្រចាំឆមាស | ប្រធានក្រុម គណៈកម្មការ ទីប្រឹក្សា និងសមាជិក | - ប្រជុំពិភាក្សារួម<br>- ពិនិត្យជាក់ស្តែង<br>- ធ្វើការសំភាសន៍ | - ពិនិត្យលើផែនការ<br>- ដោះស្រាយបញ្ហាដែលកើតមាន<br>- ថវិកាសហគមន៍ |
| ៣ | ប្រជុំប្រចាំឆ្នាំ | ប្រធានក្រុម, គណៈកម្មការ ទីប្រឹក្សា, សមាជិក នាយកដែនជម្រក | - ប្រជុំពិភាក្សារួម<br>- ពិនិត្យជាក់ស្តែង<br>- ធ្វើការសំភាសន៍ | - ពិនិត្យលើផែនការប្រចាំខែ<br>- ដោះស្រាយបញ្ហាដែលកើតមាន |

## ៨. ឯកសារឧបសម្ព័ន្ធ

- សេចក្តីប្រកាសទទួលស្គាល់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង
- ផែនទីសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង
- ផែនទីបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង
- តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ព្រាងផែនការគ្រប់គ្រងសហគមន៍
- តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍លើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍
- តារាងបញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើសេចក្តីព្រាងផែនការគ្រប់គ្រងតំបន់។

ថ្ងៃទី..05......ខែ..តុលា.....ឆ្នាំ ២០១៧

**ប្រធានសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង**

**ឡុន រិទ្ធ**

លេខ..២០៣/១៦..

បានឃើញនិងគោរពជូន

លោកនាយកដែនជម្រកសត្វព្រៃពាមក្រសោប

ដើម្បីពិនិត្យនិងជួយសម្រួល

ពាមក្រសោប,ថ្ងៃទី.......ខែ.......ឆ្នាំ ២០១៧

មេឃុំ

នាង_គុន

លេខ..........

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរបរិស្ថានខេត្តកោះកុង

ដើម្បីពិនិត្យនិងជួយសម្រួល

ពាមក្រសោប,ថ្ងៃទី.......ខែ.......ឆ្នាំ ២០១៧

នាយកដែនជម្រកសត្វព្រៃពាមក្រសោប

លេខ..........

បានឃើញនិងគោរពជូន

ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

ដើម្បីពិនិត្យនិងសម្រេច

កោះកុង,ថ្ងៃទី.......ខែ.......ឆ្នាំ ២០១៧

ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង

ម៉ិន ផល្លា

លេខ..........

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ,ថ្ងៃទី.......ខែ.......ឆ្នាំ ២០១៧

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

ខៀវ បូរិន